# CASF

Conservation Agriculture
Service with a Fee

# Conservation Agriculture Service with a Fee (CASF)



## Highlights

**Partnership agreement** with local importer to import no-till planters from Brazil

**Technical session** for private sector on economic calculation

## Development Plan

- Identify and analyze the incentives of the different private actors (farmers and service providers)
- Propose a solution (business model) that will bring in more buy-in from the different private actors
- Elaborate the business models for the CAPS interventions and support the business deals with the actors
- Provide orientation to the key project staff on Market Systems Development
- Monitor the progress and suggest corrective measures
- Provide strategic advice.

*www.swisscontact.org/cambodia*

Conservation Agriculture Service with a Fee (CASF) is a 3-year project funded by USAID. CASF interventions are also co-funded by other donors. Swisscontact is part of CASF through a MIGIP co-funding arrangement in several interventions. CASF aims to implement Conservation Agricultural Production Systems (CAPS) into Cambodian farming practices and cropping system. Shifting to innovative cropping systems and practices based on Conservation Agriculture (CA) principles will result in improved soil fertility, reduced labor, conserved water, increased yield and significantly increased income for smallholder farmers.

In the first year, 16 service providers will be introduced to CAPS, with 5 providers investing in developing the 'CAPS machinery service with a fee' for farmers. In three years of the project, 1,450 households will benefit directly from this project, 1,150 farmers will be trained in CAPS method. At the same time, 2,400 ha of conventional tilled land will be converted to no tillage with 900 ha practicing cover crops under CA technology. During the project period, 5 student interns will be trained to be CAPS extension agents, 8 field operators will be trained for CAPS service providers, 15 farmers will be trained to produce cover crop seeds, annually.

## Objectives

- Build capacities of extension staff, field operators, service providers, cover crops seed producers and farmers on CAPS
- Establish networks of entrepreneurs, retailers, service providers and farmers
- Create enabling environments that moves entrepreneurs, farmers and private service providers to shift investments from conventional tilled to CAPS.

## Activities

To achieve this vision in agriculture, MIGIP is working on the following areas:

- Increase efficiency of service provision
- Promote adoption of agriculture technology
- Improve quality of crops
- Enhance commercial orientation of agriculture technologies.

The main goal of CASF three-year project is to empower private entrepreneurs, agricultural machinery manufacturers and importers, agribusiness retailers and service providers, smallholder farmers, and public institutions to shift from conventional soil degrading agricultural production systems to profitable soil and ecosystem enhancing CAPS.



*Pearl Millet, cover crop in Bos Khnor Research Station*
*Improving soil fertility and seed production*

Funded by: FEED THE FUTURE, The U.S. Government's Global Hunger & Food Security Initiative; USAID FROM THE AMERICAN PEOPLE; Schweizerische Eidgenossenschaft, Confédération suisse, Confederazione Svizzera, Confederaziun svizra, Swiss Agency for Development and Cooperation SDC; MIGIP Mekong Inclusive Growth & Innovation Programme

Partnered with: cirad, swisscontact

Implemented by: Kansas State University; Collaborative Research on Sustainable Intensification

# CASF

Conservation Agriculture Service with a Fee

# គម្រោងសេវាកម្មកសិកម្មអភិរក្សដោយគិតកម្រៃ (CASF)



## លទ្ធផល

**កិច្ចព្រមព្រៀង១** រវាង ស្វីសខន់ថាក់ និងអ្នកនាំចូលម៉ាស៊ីនដាំដោយគ្មានការភ្ជួរពីប្រទេសប្រេស៊ីល

ផ្តល់វគ្គ **បណ្តុះបណ្តាលបច្ចេកទេស** លើការគណនាសេដ្ឋកិច្ចដល់វិស័យឯកជន

## ផែនការអភិវឌ្ឍន៍

- កំណត់ និងវិភាគការទទួលផលរបស់តួអង្គឯកជនផ្សេងៗ(កសិករ និងអ្នកផ្តល់សេវា)
- ផ្តល់ដំណោះស្រាយ (គំរូអាជីវកម្ម) ដើម្បីទទួលការគាំទ្រកាន់តែច្រើនពីផ្នែកឯកជន
- ពង្រឹងបន្ថែមលើគំរូអាជីវកម្ម សម្រាប់អន្តរាគមន៍CAPS និងគាំទ្រការចរចរអាជីវកម្មជាមួយតួអង្គសំខាន់ៗនានា
- ផ្តល់ការណែនាំដល់បុគ្គលិកគំរូរបស់គម្រោងលើការអភិវឌ្ឍប្រព័ន្ធទីផ្សារ
- តាមដានដំណើរការអនុវត្ត និងកែតម្រូវ
- ផ្តល់អនុសាស្ត្រជាលក្ខណៈយុទ្ធសាស្ត្រ។

www.swisscontact.org/cambodia

គម្រោងសេវាកម្មកសិកម្មអភិរក្សដោយគិតកម្រៃ (CASF) គឺជាគម្រោងរយៈពេល៣ឆ្នាំដែលទទួលមូលនិធិមួយផ្នែកពីទីភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់អភិវឌ្ឍន៍អន្តរជាតិ (USAID)។ ស្វីសខន់ថាក់ ចូលរួមក្នុងគម្រោង CASF តាមរយៈការផ្តល់ថវិការួមគ្នាតាមកម្មវិធីកំណើនដោយបរិយាប័ន្ន និងនវានុវត្តន៍នៃតំបន់មេគង្គ (MIGIP) នៅក្នុងអន្តរាគមន៍ផ្សេងៗ។ CASFជំរុញការអនុវត្តប្រព័ន្ធផលិតកម្មកសិកម្មអភិរក្ស (CAPS) ក្នុងវិស័យកសិកម្ម និងការដាំដុះនៅកម្ពុជា។ ការផ្លាស់ប្តូរទៅរកការអនុវត្តកសិកម្ម និងការដាំដុះដែលមានលក្ខណៈច្នៃប្រឌិត ដោយផ្អែកលើគោលការណ៍កសិកម្មអភិរក្ស នឹងជួយពង្រឹងជីជាតិដី កាត់បន្ថយកម្លាំងពលកម្ម សន្សំសំចៃទឹក បង្កើនទិន្នផល ព្រមទាំងបង្កើនចំណូលដល់កសិករខ្នាតតូច។

នៅឆ្នាំដំបូង សេវាករចំនួន១៦ត្រូវបានណែនាំឱ្យស្គាល់ពី CAPS ហើយសេវាករចំនួន៥នឹងធ្វើការវិនិយោគលើការបង្កើត «សេវាជួលម៉ាស៊ីនដល់កសិករដែលអនុវត្តប្រព័ន្ធផលិតកម្មកសិកម្មអភិរក្សដោយគិតថ្លៃ»។ ក្នុងរយៈពេល៣ឆ្នាំនៃគម្រោង ប្រជាជន ១ ៤៥០គ្រួសារ នឹងទទួលបានផលប្រយោជន៍ផ្ទាល់ពីគម្រោងនេះ ខណៈពេលដែលកសិករចំនួន ១១៥០នាក់ នឹងទទួលបានការបណ្តុះបណ្តាលបច្ចេកទេសវិធីសាស្ត្រ CAPS។ ទន្ទឹមនឹងនេះ ផ្ទៃដីដាំដុះចំនួន ២ ៤០០ ហិកតា នឹងត្រូវបានបម្លែងពីដីដាំដុះដោយភ្ជួររាស់ ទៅជាដីដាំដុះដោយគ្មានការភ្ជួររាស់ ក្នុងនោះដី ៩០០ហិកតា នឹងប្រើដំណាំគម្របដី តាមបច្ចេកទេសកសិកម្មអភិរក្ស។ ក្នុងអំឡុងពេលនៃការអនុវត្តគម្រោង និស្សិតហាត់ការចំនួន៥នាក់ នឹងត្រូវបានបណ្តុះបណ្តាលឱ្យក្លាយជាភ្នាក់ងារ CAPS ខណៈពេលប្រតិបត្តិករមូលដ្ឋានចំនួន៨នាក់នឹងត្រូវបានបណ្តុះបណ្តាលទៅជាអ្នកផ្តល់សេវា ហើយកសិករចំនួន១៥នាក់នឹងត្រូវបានបណ្តុះបណ្តាលឱ្យផលិតគ្រាប់ពូជដំណាំគម្របដី។

## គោលដៅ

- កសាងសមត្ថភាពបុគ្គលិក ប្រតិបត្តិករមូលដ្ឋាន អ្នកផ្តល់សេវា អ្នកផលិតគ្រាប់ពូជដំណាំគម្របដី និងកសិករលើប្រព័ន្ធផលិតកម្មកសិកម្មបែបអភិរក្ស (CAPS)
- បង្កើតបណ្តាញសហគ្រិន អ្នកលក់រាយ អ្នកផ្តល់សេវា និងកសិករ
- បង្កើតបរិយាកាសអំណោយផលដល់សហគ្រិន កសិករ និងអ្នកផ្តល់សេវាឯកជន ផ្លាស់ប្តូរពីការវិនិយោគលើការដាំដុះធម្មតាទៅរក CAPS

## ការអនុវត្ត

ដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យនៃវិស័យកសិកម្ម កម្មវិធី MIGIP កំពុងតែផ្តោតលើចំណុចសំខាន់ៗដូចជា៖

- បង្កើនប្រសិទ្ធភាពរបស់អ្នកផ្តល់សេវាកសិកម្ម
- លើកកម្ពស់ការចាប់យកការប្រើប្រាស់បច្ចេកវិទ្យាកសិកម្ម
- ពង្រឹងគុណភាពដំណាំ
- ធ្វើឱ្យប្រសើរឡើងនូវការធ្វើពាណិជ្ជកម្មលើបច្ចេកវិទ្យាកសិកម្ម

គោលដៅចម្បងសម្រាប់ផែនការ៣ឆ្នាំរបស់គម្រោង CASF គឺលើកស្ទួយដល់សហគ្រិនឯកជន សិប្បកម្មម៉ាស៊ីនកសិកម្ម និងអ្នកនាំចូល អ្នកអាជីវករលក់រាយនិងផ្តល់សេវាផ្នែកគ្រឿងយន្តកសិកម្ម កសិករខ្នាតតូច និងស្ថាប័នរដ្ឋ ដើម្បីផ្លាស់ប្តូរពីការអនុវត្តដែលប៉ះពាល់ដល់គុណភាពដីនិងប្រព័ន្ធការពារ ទៅជាការអនុវត្តដែលជួយដល់ដី និងមានប្រព័ន្ធអេកូឡូស៊ីដែលលើកកម្ពស់ដល់ការអនុវត្ត CAPS។



Pearl Millet ដំណាំគម្របដីពង្រឹងជីជាតិដី និងទិន្នផលគ្រប់ពូជ នៅស្ថានីយ៍ស្រាវជ្រាវបុសខ្នុរ

ឧបត្ថម្ភដោយ៖

FEED THE FUTURE — The U.S. Government's Global Hunger & Food Security Initiative

USAID FROM THE AMERICAN PEOPLE

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development and Cooperation SDC

MIGIP Mekong Inclusive Growth & Innovation Programme

សហការដោយ៖

cirad swisscontact

អនុវត្តដោយ៖

Kansas State University

Collaborative Research on Sustainable Intensification